គ្រោងការណ៍ការពារ & គាំទ្រនៃរដ្ឋកាលីហ្វ័រញ៉ា

# ការរើសអើងជនពិការ ដោយ ក្រសួងស្តារលទ្ធភាពពលកម្មកាលីហ្វ័រញ៉ា (Disability Discrimination by the California Department of Rehabilitation)[1]

*ខែវិច្ឆិកា ឆ្នាំ 2015 ការបោះពុម្ពផ្សាយលេខ #F076.06*

## តើវាខុសច្បាប់ដែរឬទេ នៅពេលក្រសួងស្តារលទ្ធភាពពលកម្ម (DOR) រើសអើងខ្ញុំ ដោយសារពិការភាពរបស់ខ្ញុំនោះ?

បាទ/ចាស ពិតជាខុសច្បាប់ ។ ក្រោម ជំពូក II នៃច្បាប់ជនពិការអាមេរិក [Title II of the Americans with Disabilities Act (ADA)] និងផ្នែក 504 នៃច្បាប់ស្តារលទ្ធភាពពលកម្ម ឆ្នាំ 1973 (Section 504 of the Rehabilitation Act of 1973) វាជាអំពើខុសច្បាប់ ដែលស្ថាប័នរដ្ឋ ឬអ្នកទទួលបានជំនួយហិរញ្ញវត្ថុសហព័ន្ធ ដូចជា DOR ជាដើម មានការរើសអើង ចំពោះបុគ្គលណាម្នាក់ ដោយសារពិការភាព ។

ឧទាហរណ៍ នៃការរើសអើង អាចរួមមាន ៖

- ការបដិសេធមិនផ្តល់សេវា ដែលធ្វើឡើងដោយ DOR ដោយសារការប្រកាន់លើ ពិការភាពជាក់លាក់ណាមួយ ។ ឧទាហរណ៍ អ្នកប្រឹក្សារបស់ DOR មួយរូប មិនអាចបដិសេធ មិនធ្វើការទូទាត់ឱ្យសាលាច្បាប់ ដោយសារតែគាត់ជឿថា បុគ្គលម្នាក់ ដែលមានភាពចុះខ្សោយ ផ្នែកចក្ខុ មិនអាចក្លាយជា មេធាវីដ៏ល្អម្នាក់ បាននោះទេ ។

---

[1] ក្រោមច្បាប់សិទ្ធិជនស៊ីវិល ឆ្នាំ 1964 (Civil Rights Act of 1964) ការរើសអើងមនុស្ស ដោយសារជាតិសាសន៍ សញ្ជាតិដើម ជាតិពិន្ទុ សាសនា និងយេនឌ័រ ជាអំពើខុសច្បាប់ ។ ច្បាប់រដ្ឋក៏បានហាមប្រាម មិនឱ្យមានការរើសអើងមនុស្ស ដោយសារស្ថានភាពគ្រួសារ និងចំណង់ចំណូលចិត្តផ្នែកផ្លូវភេទ នោះទេ ។ ទោះជាយ៉ាងនេះក្តី ទំព័រព័ត៌មាននេះ គ្រាន់តែបង្ហាញជូន អំពីការរើសអើង ដោយសារពិការភាព តែប៉ុណ្ណោះ ។

- ការខកខាន មិនបានផ្តល់សេវា ឬអត្ថប្រយោជន៍នានា នៅទីតាំង ដែលជនមានបញ្ហាផ្នែកផ្លាស់ទី អាចចូលទៅបាន ។
- ការខកខាន មិនបានធ្វើការកែសម្រួល សមហេតុផល លើគោលនយោបាយ ប្រតិបត្តិ និងនីតិវិធី ដែលចាំបាច់ ដើម្បីអនុញ្ញាត ឱ្យអ្នកដាក់ពាក្យស្នើសុំ និងអតិថិជន ជាជនពិការ អាចទទួលបាន សេវារបស់ DOR ។ ឧទាហរណ៍ ការបដិសេធ មិនព្រមធ្វើការពិចារណា លើគម្រោងពេលវែង ដើម្បីបំពេញការងារសិក្សា ដែលចាំបាច់ ឬការកែសម្រួលចំពោះពិធីសារធ្វើតេស្ត ប្រសិនបើចាំបាច់ ដោយសារពិការភាព របស់បុគ្គលណាម្នាក់ ។
- ការខកខាន មិនបានធ្វើការប្រាស្រ័យទាក់ទង ប្រកបដោយប្រសិទ្ធភាព ដូចជា ជំនួយ និងសេវា បន្ថែម (auxiliary aids and services) ។ ឧទាហរណ៍ ការមិនបានផ្តល់ ទម្រង់អេឡិចត្រូនិក (electronic format) សម្រាប់បុគ្គល ដែលមានការចុះខ្សោយ ផ្នែកចក្ខុ ឬអ្នកបកប្រែភាសាសញ្ញា ឬមធ្យោបាយប្រាស្រ័យទាក់ទង ជាអត្ថបទ សម្រាប់អតិថិជន ដែលមានបញ្ហាគថ្លង់ ។

លើសពីនេះទៅទៀត DOR មិនអាចចុះកិច្ចសន្យា ជាមួយអ្នកផ្តល់សេវា ផ្សេងទៀត ដែលមានការរើសអើង ដូចជា ការខកខានមិនផ្តល់សេវា នៅទីតាំង ដែលអាចចេញចូលបាន ឬការកែសម្រួលនានា លើវិធាន គោលនយោបាយ ឬនីតិវិធី របស់ពួកគេ ដើម្បីធានាឱ្យមាន លទ្ធភាពទទួលបានសេវា ។

## តើ DOR អាចធ្វើសេចក្តីសម្រេចថាតើ ខ្ញុំមានសិទ្ធិទទួលបានសេវា និងប្រភេទសេវា ដែលត្រូវផ្តល់ឱ្យ ផ្អែកលើពិការភាពរបស់ខ្ញុំ ដែរឬទេ?

បាទ/ចាស បាន ទៅតាមកម្រិតអនុញ្ញាត ដោយច្បាប់ ។ DOR ផ្តល់សេវានានា ជូនជនពិការ ដើម្បីជួយពួកគេ ឱ្យត្រឡប់ទៅ បំពេញការងារវិញបាន ទទួលបានការងារពេលចេញទៅធ្វើការលើកដំបូង ទទួលបានការបណ្តុះបណ្តាល ដើម្បីទទួលបានអាជីពថ្មី និងរក្សាឱ្យបានការងារបច្ចុប្បន្ន ។ DOR ភ្ជាប់ការកំណត់លើសិទ្ធិទទួលបាន និងសេវានានា ទៅនឹងលក្ខខណ្ឌតម្រូវ ដូចមានកំណត់ដោយច្បាប់ ក្រោមច្បាប់ស្តារលទ្ធភាពពលកម្មសហព័ន្ធ (federal Rehabilitation Act) ព្រមទាំងច្បាប់ និងបទបញ្ញត្តិ ស្តីពីការស្តារលទ្ធភាពពលកម្មវិជ្ជាជីវៈ រដ្ឋកាលីហ្វ័រញ៉ា (California's vocational rehabilitation statute and regulations) ។ ច្បាប់តម្រូវឱ្យ DOR ធ្វើការកំណត់ ដោយផ្អែកលើ សមត្ថភាព និងពិការភាព របស់អ្នកដាក់ពាក្យស្នើសុំ/អតិថិជន ព្រមទាំង ចំណង់ចំណូលចិត្តរបស់ពួកគេ ។

ឧទាហរណ៍ សេចក្តីបង្គាប់របស់បទបញ្ញត្តិ ស្តីពីការជ្រើសរើស (order of selection regulations) អនុញ្ញាតឱ្យ DOR កំណត់អាទិភាពលើសេវានានា ចំពោះជនពិការមួយចំនួន ដោយផ្អែកលើកម្រិតធ្ងន់ធ្ងរ និងប្រភេទ ពិការភាព នៅពេលថវិការដ្ឋ

មានកម្រិត ។  ជាមួយគ្នានេះផងដែរ ក្រោមក្រមខ័ណ្ឌច្បាប់ និងបទបញ្ញត្តិរបស់ខ្លួន DOR ធ្វើការកំណត់ថាតើ បុគ្គលម្នាក់ មានសិទ្ធិទទួលបាន សេវាស្តារលទ្ធភាពពលកម្មវិជ្ជាជីវៈ ដោយផ្អែកលើការចុះខ្សោយ ផ្នែករាងកាយ ឬផ្នែកផ្លូវចិត្ត របស់បុគ្គលនោះ ឬយ៉ាងណានោះ ឬថាតើ ការចុះខ្សោយនោះ បង្ករជាឧបសគ្គ ដល់ការងាររបស់គាត់ ឬយ៉ាងណានោះ ។  ជាងនេះទៅទៀត ដើម្បីទទួលបានការកំណត់ថា មានសិទ្ធិទទួលបានសេវា បុគ្គលម្នាក់ត្រូវបង្ហាញថា គាត់ត្រូវការ សេវាស្តារលទ្ធភាពពលកម្មវិជ្ជាជីវៈ និងថា គាត់អាចទទួលបាន អត្ថប្រយោជន៍ ពីសេវារបស់ DOR ។

នៅពេលបុគ្គលម្នាក់ ត្រូវបានកំណត់ថា មានសិទ្ធិទទួលបានសេវា បុគ្គលនោះត្រូវទទួលខុសត្រូវលើ ការជ្រើសរើស គោលដៅការងាររបស់ខ្លួន និងសេវានានា ដោយផ្អែកលើ ចំណាប់អារម្មណ៍ សមត្ថភាព និង «ជម្រើស ដែលសម្រេច ដោយមានព័ត៌មានពេញលេញ (informed choice)» ។  សម្រាប់ព័ត៌មានបន្ថែម អំពីជម្រើសដែលសម្រេចដោយមានព័ត៌មានពេញលេញ សូមមើលទំព័រព័ត៌មាន របស់ CAP http://www.disabilityrightsca.org/pubs/554001.pdf

DOR អាចធ្វើការកំណត់ នាពេលអនាគតថា សេវារបស់បុគ្គលម្នាក់ អាចត្រូវបានផ្លាស់ប្តូរ ឬកាត់បន្ថយ ដោយផ្អែកលើ វឌ្ឍនភាព ក្នុងកម្រិតមិនគ្រប់គ្រាន់ ក្នុងការសម្រេចឱ្យបានគោលដៅរបស់គាត់ ។  ទោះជាយ៉ាងនេះក្តី ប្រភេទពិការភាពដែលអតិថិជនមាន មិនគួរជាកត្តាកំណត់ លើសិទ្ធិទទួលបាន ឬការផ្តល់ សេវា នោះទេ ។

ខណៈដែលស្ថាប័នរដ្ឋ ជាទូទៅ មិនអាចបដិសេធ មិនផ្តល់សេវា ដោយសារពិការភាពនោះ, បទបញ្ញត្តិសហព័ន្ធ អាចអនុញ្ញាតឱ្យ ស្ថាប័នរដ្ឋ ដូចជា DOR ធ្វើការមិនរាប់បញ្ចូល ឬរាប់បញ្ចូល ជនពិការ នៅក្នុងកម្មវិធីរបស់ពួកគេបាន ។  34 ក្រមបទបញ្ញត្តិសហព័ន្ធ [34 Code of Federal Regulations (C.F.R.)] §104.4(c).  នេះអនុញ្ញាតឱ្យ DOR អាចផ្តល់ ឬបដិសេធ មិនផ្តល់សេវា ដោយផ្អែកលើពិការភាពរបស់បុគ្គលណាម្នាក់ ប្រសិនបើការធ្វើបែបនេះ អនុលោមតាមច្បាប់ និងបទបញ្ញត្តិ របស់កម្មវិធី ។  ការធ្វើបែបនេះ មិនរំលោភបំពានលើ ច្បាប់ ស្តីពីការរើសអើង ដូចជា ADA ឬ ផ្នែក (Section) 504 នោះទេ ។

## តើអតិថិជន អាចធ្វើអីបាន ប្រសិនបើពួកគេ មិនយល់ស្របនឹង ការសម្រេច របស់អ្នកប្រឹក្សា DOR ?

ដូចមានពិភាក្សាខាងលើរួច ការសម្រេចជាច្រើន ដែល DOR ធ្វើឡើង មិនមែនសុទ្ធតែជាការរើសអើង ដែលជាអំពើខុសច្បាប់នោះទេ ។  ផ្ទុយទៅវិញ ការសម្រេចទាំងនោះ អាចបង្ករឱ្យមាន ការយល់ស្របគ្នា ឬជម្លោះ រវាង អ្នកដាក់ពាក្យស្នើសុំ/អតិថិជន និង DOR ។  ឧទាហរណ៍ ការមិនយល់ស្របគ្នា អាចកើតមានចំពោះចំណុច ដែលថាតើគោលដៅការងារជាក់លាក់ណាមួយ អាចសម្រេចបាន ឬសេវា ឬការសិក្សា ជាក់លាក់ណាមួយ ជាការចាំបាច់ ឬយ៉ាងណានោះ ។  ប្រភេទជម្លោះបែប

នេះ អាចដោះស្រាយ បានល្អបំផុត តាមរយៈ ដំណើការដោះស្រាយជម្លោះរបស់ DOR ដែលអាចមាន ការពិនិត្យឡើងវិញ ដោយអ្នកចាត់ការរបស់ DOR លើការស្នើសុំ ការពិនិត្យឡើងវិញលើអ្នកគ្រប់គ្រងមណ្ឌល (District Administrator review) ការសម្របសម្រួល ឬសវនការ ប្រកបដោយយុត្តិធម៌ ។ សម្រាប់ព័ត៌មានបន្ថែម អំពីការដោះស្រាយជម្លោះ ជាមួយ DOR សូមមើលទំព័រព័ត៌មាន DRC CAP អំពីសេវារបស់ DOR ដែលចាប់ផ្តើម នៅសំណួរទី 31 នៅឯ [http://www.disabilityrightsca.org/pubs/540101.pdf.](http://www.disabilityrightsca.org/pubs/540101.pdf)

## ខ្ញុំគិតថា ខ្ញុំត្រូវបាន DOR រើសអើង ដោយខុសច្បាប់ ។ តើខ្ញុំអាចដាក់ពាក្យបណ្តឹងបាន នៅឯណាដែរ?

ប្រសិនបើលោកអ្នកត្រូវបានរើសអើង ដោយ DOR លោកអ្នកអាចដាក់ ពាក្យបណ្តឹងរដ្ឋបាលបាន ក្រោម ADA និង ផ្នែក (Section) 504 ។ លោកអ្នកមានរយៈពេល តែ 180 *ថ្ងៃប៉ុណ្ណោះ* គិតចាប់ពី កាលបរិច្ឆេទ ដែលមានអំពើរើសអើង ចុងក្រោយនោះ ដើម្បីដាក់ពាក្យបណ្តឹងរដ្ឋបាល ។ ដំបូង លោកអ្នកអាចដាក់ពាក្យបណ្តឹងទៅ ការិយាល័យសិទ្ធិជនស៊ីវិល របស់ DOR [Office of Civil Rights (OCR)] ដោយទំនាក់ទំនង ទៅពួកគេ នៅ ៖

Department of Rehabilitation
Office of Civil Rights
721 Capitol Mall
Sacramento, CA 95814
(916) 558-5850 (ទូរសព្ទ)
(916) 558-5852 (TTY)

លោកអ្នកក៏អាច ដាក់ពាក្យបណ្តឹង ទៅ ការិយាល័យសិទ្ធិជនស៊ីវិល នៃក្រសួងអប់រំសហរដ្ឋអាមេរិក [U.S. Department of Education’s (DOE’s) OCR] ដោយបំពេញបែបបទ នៅ [http://www2.ed.gov/about/offices/list/ocr/complaintintro.html](http://www2.ed.gov/about/offices/list/ocr/complaintintro.html) ឬដោយទំនាក់ទំនង ទៅ ៖

U.S. Department of Education
Office for Civil Rights
50 Beale Street, Ste. 7200
San Francisco, CA 94105
(415) 486-5555 (ទូរសព្ទ)
(877) 521-2172 (TTY)

លោកអ្នកក៏អាច ដាក់ពាក្យបណ្តឹងទៅ ក្រសួងយុត្តិធម៌ សហរដ្ឋអាមេរិក [U.S. Department of Justice (DOJ)] បានផងដែរ ដោយទូរសព្ទទៅ (800) 514-0301 (សម្លេង) ឬ (800) 514-0383 (TTY) ។ DOJ មានអំណាចយុត្តាធិការ តែលើ ADA ប៉ុណ្ណោះ មិនមែនលើ ផ្នែក (Section) 504 នោះទេ ។

## តើមានវិធីណា ដែលខ្ញុំអាចដាក់ពាក្យបណ្តឹងបាន ប្រសិនបើខ្ញុំត្រូវបានរើសអើង ដោយ DOR ក្នុងរយៈពេលលើសពី 180 ថ្ងៃនោះ?

បុគ្គលម្នាក់អាចដាក់ពាក្យបណ្តឹង ក្រោមច្បាប់ស៊ីវិល អាន់រី កាលីហ្វ័រញ៉ា [California's Unruh Civil Act ("the Unruh Act")][2] ទៅក្រសួងការងារ និងលំនៅដ្ឋាន ប្រកបដោយយុត្តិធម៌ កាលីហ្វ័រញ៉ា [California's Department of Fair Employment and Housing (DFEH)] ក្នុងរយៈពេល *មួយឆ្នាំ* ចំពោះអំពើរើសអើងថ្មីៗ បំផុត ។ លោកអ្នកអាចចូលទៅមើល DFEH នៅលើអ៊ីនធឺណែត នៅឯ www.dfeh.ca.gov ឬទូរសព្ទទៅពួកគេ តាមរយៈលេខ (800) 884-1684 ដើម្បីកំណត់កាលបរិច្ឆេទណាត់ជួប រៀបចំដាក់ពាក្យបណ្តឹង ។

## តើខ្ញុំអាចដាក់ពាក្យបណ្តឹង តតាំងនឹង DOR បានដែរឬទេ?

បាទ/ចាស បាន ។ ពាក្យបណ្តឹងអំពីការរើសអើង អាចដាក់បាន ទាំងនៅតុលាការសហព័ន្ធ ឬតុលាការរដ្ឋ ក្នុងរយៈពេល *ពីរឆ្នាំ* ចំពោះអំពើរើសអើង ថ្មីៗ បំផុត ។ បណ្តឹង អាចធ្វើឡើង ក្រោម ADA ផ្នែក (Section) 504 ឬច្បាប់រដ្ឋ ។ លោកអ្នកមិនចាំបាច់ត្រូវដាក់ពាក្យបណ្តឹងទៅ ការិយាល័យសិទ្ធិជនស៊ីវិល នៃក្រសួងយុត្តិធម៌ (Offices of Civil Rights, DOJ) ឬ DFEH ដើម្បីធ្វើការប្តឹងប្តល់ ទៅតុលាការរដ្ឋ ឬតុលាការសហព័ន្ធនោះទេ ។ ប្រសិនបើលោកអ្នកមានចំណាប់អារម្មណ៍ នឹងចាត់វិធានការបែបនេះ នោះលោកអ្នកចាំបាច់ត្រូវពិគ្រោះជាមួយ និងជួលមេធាវីតំណាងឱ្យលោកអ្នក ។ លោកអ្នកអាចទៅសាកសួរ មេធាវី CAP របស់លោកអ្នកបាន ដោយទូរសព្ទទៅលេខ (800) 776-5746 ដើម្បីឱ្យដឹងថាតើ គាត់មាន បញ្ជីបញ្ជូនទៅមេធាវី (attorney referral list) ឬយ៉ាងណានោះ ។

*>សិទ្ធិជនពិការកាលីហ្វ័រញ៉ា (Disability Rights California) ទទួលបានមូលនិធិគាំទ្រ ពីប្រភពផ្សេងៗ ជាច្រើន ដើម្បីស្វែងយល់ អំពីបញ្ជីអ្នកផ្តល់មូលនិធិទាំងស្រុង សូមចូលទៅ http://www.disabilityrightsca.org/Documents/ListofGrantsAndContracts.html.*

---

[2] ការរំលោភបំពានលើ ADA គឺជាការរំលោភបំពាន លើច្បាប់អាន់រី (Unruh Act) ។ សូមមើល ផ្នែក (Part) 2 នៃក្រមស៊ីវិលកាលីហ្វ័រញ៉ា (California Civil Code) § 51(f) ។